00194685

**Declassified to Public**
**06 September 2012**

ឯកសារ/No D 93

០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស

# ការិយាល័យ នៃសហចៅក្រមស៊ើបអង្កេត
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស

បញ្ជូនទៅ: ការិយាល័យសហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី០២ ខែ មិថុនា ឆ្នាំ២០០៨

ភាគីបញ្ជូន: សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ភាសាដើម: ខ្មែរ និងអង់គ្លេស

ប្រភេទឯកសារ: សំខាត់

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 06 / 2008
ម៉ោង (Time/Heure): 8 : 50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## សំណើសុំរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឱ្យមានការស៊ើបអង្កេតបន្ថែមដោយអនុលោមតាមវិធាន ៦៦ (១) នៃវិធានផ្ទៃក្នុង

**បញ្ជូនដោយ :**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គឹមសួន

លោក យុង ផានិត

លោក គង់ ពិសី

លោកស្រី Silke Studzinsky

**ចែកចាយជូន :**

**អង្គបុរេជំនុំជម្រះ**

លោក យូ ប៊ុនឡេង

លោក Marcel Lemonde

**មេធាវីការពារក្តី ឡេចអ៊ាវ**

លោក ការ សាវុត្ថ

លោក Francois Roux

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / 06 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## I- សាវតានីតិវិធី

១. នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨ ការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា ក.ស.ច.ស) បានចេញសេចក្ដីជូនដំណឹងអំពីការសន្និដ្ឋាននៃការស៊ើបអង្កេតរបស់តុលាការ។

២. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៨ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលការជូនដំណឹងអំពីសេចក្ដីសម្រេចនេះ។

៣. ភ្ជាប់ជាមួយសំណើសុំនេះ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសូមដាក់សំណើសុំឱ្យមានការស៊ើបអង្កេតបន្ថែម ដោយអនុលោមតាមវិធាន ៦៦ (១) នៃវិធានផ្ទៃក្នុង។

## II. សេចក្ដីផ្ដើម

៤. ដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី ភុង ស៊ុនថារី(PHUNG Sunthary)និងលោក ជុំ ស៊ីរ៉ាត ស្នើសុំឱ្យសួរចម្លើយជនត្រូវចោទអំពីសេចក្ដីលំអិតនៃគ្រោះកម្មរបស់សាច់ញាតិពួកគេដែលត្រូវបានគេសម្លាប់នៅក្នុងស-២១។

៥. ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរត្រូវគេទទួលស្គាល់នៅពេលថ្មីៗនៅក្នុងសំណុំរឿងនេះ។ អាស្រ័យហេតុនេះ ពួកគេមិនមានលក្ខណៈសម្បត្តិដើម្បីស្នើសុំឱ្យមានការស៊ើបអង្កេតពីមុនមកទេ។

៦. ជនត្រូវចោទស្គាល់សាច់ញាតិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ខ្លួន ហើយគេជឿជាក់ថាជនត្រូវចោទដឹងពត៌មានលំអិតដែលបានកើតឡើងចំពោះពួកគេនោះ។

៧. ដើមបណ្ដឹងរដ្ឋប្បវេណីមានការចាប់អារម្មណ៍ផ្ទាល់ខ្លួនយ៉ាងជ្រាលជ្រៅ ដើម្បីដឹងឱ្យលំអិតអំពីស្ថានភាព នៃការឈឺចាប់របស់សមាជិកគ្រួសាររបស់ពួកគេដែលទទួលរងគ្រោះនៅក្នុងស-២១ ហើយជនត្រូវចោទ នឹងអាចផ្ដល់ពត៌មានទាំងនេះបានដល់ពួកគេ។

៨. ដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឱ្យមានការស៊ើបអង្កេតពត៌មានទាំងនេះនៅកំឡុងពេលនេះ ព្រោះវាមិនប្រាកដថាពួកគេនឹងអាចផ្ដល់ពត៌មានទាំងនេះនៅក្នុងដំណាក់កាលជំនុំជម្រះនោះទេ ដោយហេតុថាមកពីកត្តាពេលវេលា និងភាពមិនប្រាកដប្រជាដ៏ទៃទៀត។ ដើមបណ្ដឹងរដ្ឋប្បវេណីចង់បានយ៉ាងខ្លាំងដែលថានីតិវិធីដើរទៅមុខ និងការជំនុំជម្រះចាប់ផ្ដើមឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ស្របពេលគ្នានេះដែរ ពួកគេបានរងចាំអស់រយៈពេលដ៏សែនយូរនៅក្នុងភាពមិនប្រាកដប្រជា ដែលគួរឱ្យឈឺចាប់ដើម្បីរកឱ្យឃើញការពិត ថាតើមានអ្វីខ្លះដែលកើតឡើងចំពោះមនុស្សជាទីស្រលាញ់របស់ពួកគេ។

៩. នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាកោះហៅជនត្រូវចោទ ដើម្បីសួរចម្លើយម្តងទៀត នៅថ្ងៃទី ២, ៣, ២៤ និង ២៥ ខែ មិថុនា ឆ្នាំ ២០០៨។ អាស្រ័យហេតុនេះ នីតិវិធីនេះនឹងមិនត្រូវអូសបន្លាយពេលដោយសារការស្នើសុំរបស់យើងខ្ញុំនោះទេ។

**III. សំណើសុំរបស់នាគីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី ភុង ស៊ុនថារី** (PHUNG Sunthary)

១០. ឪពុករបស់លោកស្រីភុង ស៊ុនថារី(PHUNG Sunthary)លោក ភុង តុន(PHUNG Ton) ត្រូវគេឃុំឃាំងក្នុងគុក ទួលស្លែងនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៦។ **ឌុច** បានស្គាល់ និងចងចាំគាត់យ៉ាងច្បាស់។ លោក ភុង តុន ធ្លាប់បានធ្វើជាព្រឹទ្ធបុរសកិត្តិយសនៃសកលវិទ្យាល័យភ្នំពេញ។

**១១. សំណួរដែលសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យសួរមានដូចខាងក្រោម :**

១- តើនរណាជាអ្នកចេញបញ្ជា និងសម្រេចឱ្យឃុំឃាំងលោក ភុង តុន ក្នុងមន្ទីរស-២១ គុកទួលស្លែង ? ដោយសារមូលហេតុអ្វី ? តើការសំរេចឃុំឃាំងធ្វើឡើងនៅពេលណា ?

២- តើគេប្រព្រឹត្តបែបណាខ្លះចំពោះគាត់ក្នុងគុកទួលស្លែង ? តើគេមានធ្វើទារុណកម្មគាត់ដែរឬទេ? តើគេចាត់វិធានការបែបណាខ្លះចំពោះគាត់ ? តើនរណាជាអ្នកចេញបញ្ជាឱ្យមានការប្រើវិធានការទាំងនោះ?

៣- តើគេមានសួរចំលើយគាត់ដែរឬទេ ? នរណាជាអ្នកសួរ ? ហើយតើគេបានចំលើយអ្វីខ្លះពីគាត់?

៤- តើឌុចធ្លាប់មានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយលោក ភុង តុន នៅក្នុងគុកទួលស្លែងដែរឬទេ ? បើមានតើការទាក់ទងនោះកើតឡើងយ៉ាងដូចម្តេចខ្លះ ?

៥- តើហេតុអ្វីបានជាលោក ភុង តុន អាច"**នៅរស់**"ក្នុងមន្ទីស-២១បានយូរជាងអ្នកទោសដទៃទៀត (ជិត៦ខែ)? នេះគឺដោយសារតែគាត់មិនព្រម "សារភាព" ឬ ?

៦- តើគាត់ស្លាប់របៀបណា ហើយនៅកន្លែងណា ?
តាមឯកសារបង្ហាញថាគាត់ត្រូវគេពិនិត្យសុខភាព និងចុងក្រោយគេបញ្ជាក់ថាគាត់មានសុខភាពមិនល្អនៅថ្ងៃទី៦ ខែ កក្កដា ឆ្នាំ ១៩៧៧។

៧-តើនរណាជាអ្នកចេញបញ្ជាឱ្យគេសម្លាប់គាត់ ?តើបញ្ជានេះត្រូវគេចេញតាំងពីមុនយូរហើយឬ? លោក **កេង វ៉ាន់សាក់** ដែលរស់នៅប្រទេសបារាំងបានបញ្ជាក់ថាបញ្ជានេះត្រូវគេចេញជាយូរមកហើយ។

## IV. សំណើរសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីលោក ជុំ ស៊ីរ៉ាត

១២. ដើមបណ្តឹងរដ្ឋប្បវេណី លោក ជុំ ស៊ីរ៉ាត បានបាត់ប្អូនប្រុសពីរនាក់ គឺលោក ជុំ ស៊ីណារ៉េត លោក ជុំ ណារិត និងប្រពន្ធ។ **ឌុច** គឺជាគ្រូបង្រៀននៅស្គន់ ហើយគេដឹងថា**ឌុច**បានស្គាល់លោក ជុំ ណារិត ដែលមកពីស្រុកជាមួយគ្នា ហើយក៏ជាគ្រូបង្រៀនផងដែរ ប៉ុន្តែមិនមែនធ្វើគ្រូនៅស្គន់ទេ។ក្នុងចំលើយសារភាព របស់ **ហ៊ូ នឹម**[១] មានបញ្ចេញឈ្មោះលោកជុំ ណារិត ថាជាផ្នែកមួយនៃក្រុម បញ្ញវ័ន្តសេរី។

១៣. **សំណួរដែលសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យសួរមានដូចខាងក្រោម :**

១- តើនរណាជាអ្នកចេញបញ្ជា និងសម្រេចឱ្យឃុំឃាំងប្អូនប្រុសទាំងពីរ និងប្អូនថ្លៃរបស់គាត់? តើការឃុំឃាំងនោះធ្វើនៅពេលណា ហើយគេធ្វើយ៉ាងម្តេចខ្លះ? តើការឃុំឃាំងលោក **ស៊ី ណារ៉េត** និង **ណារិត** ត្រូវគេធ្វើឡើងក្នុងពេលតែមួយឬទេ ?

២- តើគេប្រព្រឹត្តអ្វីខ្លះមកលើអ្នកទាំងបីនេះក្នុងគុកទួលស្លែង ? តើគេធ្វើទារុណកម្មពួកគាត់ដែរឺទេ? តើអ្នកទាំងបីនេះទទួលសារភាពដែរឺឬទេក្រោមការធ្វើទារុណកម្ម? បើពួកគេសារភាព តើពួកគេឆ្លើយថាម៉េចខ្លះ?

៣- តើ **គឹម សុវណ្ណារី** មានកូនដែរឺទេ ? ហើយតើមានរឿងអ្វីខ្លះដែលកើតឡើងចំពោះពួកគេ ?

៤- តើពួកគេត្រូវគេសម្លាប់ដោយរបៀបណា នៅកន្លែងណា និងពេលណា ?

៥- តើ **ឌុច** បានដឹងថាបច្ចុប្បន្ន គ្រួសាររបស់**គឹម សុវណ្ណារី** រស់នៅកន្លែងណាដែរឺទេ ?

៦- តើ **ឌុច** អាចផ្តល់ពត៌មានបន្ថែមអំពីប្រជាពលរដ្ឋដែលត្រូវគេសម្លាប់ដែរឺទេ ?

**គោរពជូនពី**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**ហុង គឹមសួន**

មេធាវីមកពីអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

---

[១] David P. Chandler, Ben Kierman, Chantou Boua ក្នុងអត្ថបទស្តីអំពី "ប៉ុលពតរៀបចំផែនការនាថ្ងៃអនាគត" ទំព័រ ២៦៨,២៧០។

00194689



**យុង ផានិត**

មេធាវីមកពីអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

**Silke Studzinsky**

មេធាវី

បានចុះហត្ថលេខានៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៨

ភ្នំពេញ